**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម ប្យ៊ន់ ហេគម៉ាក ឯកអគ្គរាជទូតស៊ុយអែតប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

នៅព្រឹកថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បាន អនុញ្ញាតឲ្យ **ឯកឧត្តម ប្យ៊ន់ ហេគម៉ាក** (Björn Häggmark) ឯកអគ្គរាជទូតស៊ុយអែតប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែល**ឯកឧត្តម**បានបញ្ចប់បេសកកម្មការទូត នៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសាទរចំពោះ **ឯកឧត្តមឯកអគ្គរាជទូត** ដែលបានបំពេញបេសកកម្មការទូតនៅកម្ពុជាបានល្អ និងបានថ្លែងអំណរគុណចំពោះការចូលរួមចំណែករបស់**ឯកឧត្តម**ក្នុងការលើកកម្ពស់ និងពង្រឹងនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកពីប្រវត្តិទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អ ដែលប្រទេសស៊ុយអែតបានផ្តល់មកកម្ពុជា ជាពិសេស គឺការអនុញ្ញាតិអោយកម្ពុជាបើកការិយាល័យតំណាងនៅស៊ុយអែតក្រោយពីកម្ពុជាត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលស៊ុយអែតដែលបានផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា តាមរយៈទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែត ក្នុងវិស័យកសិកម្ម អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈការងារ បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់ថ្នាក់ក្រោមជាតិនៅកម្ពុជា ព្រមទាំងការផ្តល់ជំនួយនាំមុខគេតាំងពីឆ្នាំ២០០៦ ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ផងដែរ។

ជាការឆ្លើយតប **ឯកឧត្តមឯកអគ្គរាជទូត** បានបញ្ជាក់ថា ស៊ុយអែតក៏នឹងបន្តជួយសាលាក្តីខ្មែរក្រហមរហូតដល់សាលាក្តីនេះបានបញ្ចប់ភារកិច្ចសព្វគ្រប់។ **ឯកឧត្តមឯកអគ្គរាជទូត** បានថ្លែងអំណរគុណជាពិសេសជូនចំពោះ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលទទួលសវនាការជម្រាបលារបស់ឯកឧត្តមនៅក្នុងពេលវេលានេះ និងកិច្ចសហប្រតិបត្តិការដ៏ល្អរបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានជួយគាំទ្រ និងរួមចំណែកធ្វើឱ្យបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជាទទួលបានជោគជ័យ ។ **ឯកឧត្តមឯកអគ្គរាជទូត** ក៏បានឯកភាពថា ប្រទេសកម្ពុជា និងស៊ុយអែតពិតជា

មានទំនាក់ទំនងពិសេសយូរអង្វែងចាប់ពីស្ថានភាពលំបាករហូតដល់បច្ចុប្បន្ន។ ដោយឡែក ស៊ុយអែតបានស្នើសុំជាផ្លូវការបើកស្ថានកុងស៊ុលកិត្តិយសនៅភ្នំពេញ។

ភាគីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីដ៏ល្អលើគ្រប់វិស័យ ទោះបីជារដ្ឋាភិបាលស៊ុយអែតបានសម្រេចបិទស្ថានឯកអគ្គរាជទូតនៅទីក្រុងភ្នំពេញ ដែលបណ្តាលមកពីការធ្វើកំណែទម្រង់ និងសម្ពាធផ្នែកថវិការបស់ស៊ុយអែតយ៉ាងណាក៏ដោយ ក៏ស៊ុយអែតនៅតែបន្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយកម្ពុជា តាមរយៈស្ថានឯកអគ្គរាជទូតស៊ុយអែតដែលមាននិវេសនដ្ឋាននៅទីក្រុងបាងកក និងការិយាល័យតំណាងនៅភ្នំពេញ ដែលមានបុគ្គលិកមកពីទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែត ( Swedish International Development Cooperation Agency -SIDA ) នៅភ្នំពេញ និងតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ចំពោះមុខ សម្រាប់ឆ្នាំ ២០២២-២០២៦ ដែលយកចិត្តទុកដាក់នឹងការលើកកម្ពស់សិទ្ធិមនុស្ស និង ស្ថាប័នប្រជាធិបតេយ្យអនុលោមតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា។

ព្រមជាមួយនេះ ភាគីទាំងពីរចូលរួមកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីជម្នះជំងឺរាតត្បាតកូវីដ-១៩ ទន្ទឹមនឹងជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចាក់ថ្នាំបង្ការជូនប្រជាពលរដ្ឋបាន ៤៥% គិតត្រឹមថ្ងៃទី៤ ខែកក្កដា កន្លងទៅនេះ។

តួអង្គសំខាន់ក្នុងការជំរុញការផ្លាស់ប្តូរពាណិជ្ជកម្ម ដែលអំណោយផលដល់កម្ពុជា គឺក្រុមហ៊ុនកាត់ដេរ H&M ដែលមានបំណងបន្តវត្តមាននៅកម្ពុជា ហើយយកចិត្តទុកដាក់នឹងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងនោះ គឺការយកចិត្តទុកដាក់នឹងការប្រែប្រួលអាកាសធាតុ ដោយគោរពការពារបរិស្ថាន ប្រើប្រាស់ថាមពលដែលកកើតឡើងវិញបាន លក្ខខ័ណ្ឌការងារ ការបណ្តុះបណ្តាលពលករ និងការគោរពយេនឌ័រ។

ក្រៅពីទំនាក់ទំនងទ្វេភាគី ភាគីទាំងពីរក៏បានពិភាក្សាប្តូរយោបល់គ្នាផងដែរលើប្រធានបទផ្សេងៗដូចជាបញ្ហាតំបន់ រួមមានបញ្ហាអាស៊ាន ដូចជាការត្រៀមលក្ខណៈរបស់កម្ពុជាក្នុងការធ្វើប្រធានអាស៊ាន បញ្ហាមីយ៉ាន់ម៉ា សមុទ្រចិនខាងត្បូង និងឥណ្ឌូប៉ាស៊ីហ្វិក។ ដោយឡែកលើបញ្ហាសកល ភាគីទាំងពីរមានជំហរដូចគ្នាលើការពង្រឹងពហុនិយម និងការគោរពគោលការណ៍ និងច្បាប់អន្តរជាតិ។

នាចុងបញ្ចប់នៃជំនួប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានជូនពរឯកឧត្តម **ហ្សិន ហេគម៉ាក** ទទួលបានជោគជ័យជាបន្តទៀតនៅក្នុងភារកិច្ចថ្មីនាពេលខាងមុខរបស់ឯកឧត្តម ៕

-----------